មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ នួន ម៉ុក ភេទប្រុស អាយុ៧១ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈ "យោធា"**

**ស្រុកកំណើតនៅភូមិតាំងក្រសៅ ឃុំតាំងក្រសៅ ស្រុកសន្ទុក ខេត្តកំពង់ធំ**

**រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សោម ប៊ុនថន**

**០១:២៦:២៩**

**២៥ទំព័រ**

ប៊ុនថនៈ ខ្ញុំចង់ណែនាំខ្លួនខ្ញុំដែរ ខ្ញុំឈ្មោះ ប៊ុនថន ហើយសម្ភាសពូ ហើយខ្ញុំកត់ត្រាក្នុងសៀវភៅដោយសារខ្ញុំកត់ត្រាមិនទាន់ខ្ញុំសុំថតជាសម្លេង?

ម៉ុកៈ បាទ ។

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

ម៉ុកៈ នួន ម៉ុក ។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយ?

ម៉ុកៈ អាយុ៧១ហើយ ។

ប៊ុនថនៈ ពូមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ម៉ុកៈ ឃុំតាំងក្រសៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

ប៊ុនថនៈ ឃុំអីវិញពូ?

ម៉ុកៈ ឃុំតាំងក្រសៅ ។

ប៊ុនថនៈ ចឹងបច្ចុប្បន្ននៅរស់នៅភូមិឃុំអីដែរ?

ម៉ុកៈ ស្តាប់មិនបាន ។

ប៊ុនថនៈ ពូមានបងប្អូនប៉ុន្មាននាក់?

ម៉ុកៈ មាន៦នាក់ ។

ប៊ុនថនៈ ពូកូនទីប៉ុន្មាន?

ម៉ុកៈ កូនទី២ ។

ប៊ុនថនៈ ពូអាចរៀបរាប់ឈ្មោះ បងប្អូនបានទេ ទី១ឈ្មោះអីវិញ?

ម៉ុកៈ ឈ្មោះ នួន វ៉ន ។

ប៊ុនថនៈ គាត់នៅរស់ដែរ?

ម៉ុកៈ	នៅរស់ ។

ប៊ុនថនៈ	គាត់នៅរស់នៅណាដែរ?

ម៉ុកៈ	រស់នៅស្រុកកំណើត ។

ប៊ុនថនៈ	ទី២?

ម៉ុកៈ	ទី២ ឈ្មោះ នួន សុខ ស្លាប់ ។

ប៊ុនថនៈ	ប្រុស?

ម៉ុកៈ	ប្រុស ។

ប៊ុនថនៈ	ទី៣?

ម៉ុកៈ	ទី៣ឈ្មោះ នួន ហ៊ុន ស្លាប់ដែរ ។

ប៊ុនថនៈ	ប្រុស?

ម៉ុកៈ	ប្រុស ។

ប៊ុនថនៈ	ទី៤?

ម៉ុកៈ	ទី៤ នួន ឃន ភេទស្រី ។

ប៊ុនថនៈ	គាត់នៅរស់?

ម៉ុកៈ	នៅរស់ រស់នៅខេត្តកំពង់ធំ ។

ប៊ុនថនៈ	ទី៥?

ម៉ុកៈ	ទី៥ ស្លាប់ ប្រុស ឈ្មោះ នួន សាន់ ។

ប៊ុនថនៈ	ទី៦ពូ?

ម៉ុកៈ	ងាប់បីរស់បី មើលរស់បងទី១ និងខ្ញុំ រស់បីងាប់បី មាន៦នាក់ ។

ប៊ុនថនៈ	ចឹងឈ្មោះ នួន សៅ កូនទី៦?

ម៉ុកៈ	បាទ ។

ប៊ុនថនៈ	ពូកាលពីក្មេងបានរៀនសូត្រនៅភូមិឃុំអីដែរ?

ម៉ុកៈ	រៀននៅស្រុកហ្នឹងភូមិហ្នឹង ។

ប៊ុនថនៈ	រៀននៅសាលាណាពូ?

ម៉ុកៈ	សាលាវត្តលោកហ្នឹង លោកបង្ហាត់ មិនបានរៀនណាណីទេ រៀនបានបន្តិចបន្តួចលែងធ្វើស្រែចម្ការទៅ ។

ប៊ុនថនៈ	សាលាវត្តតាំងក្រសៅហ្នឹង?

ម៉ុកៈ	វត្តគោកស្រុក ។

ប៊ុនថន: នៅក្នុងឃុំតាំងក្រសៅ?

ម៉ុក: ឃុំតាំងក្រសៅ ។

ប៊ុនថន: ពូនៅសាលាវត្តហ្នឹងរៀនបានប៉ុន្មានឆ្នាំ?

ម៉ុក: រៀនបានមួយឆ្នាំហ្នឹង ។

ប៊ុនថន: ស្តាប់មិនបាន.....

ម៉ុក: .......................

ប៊ុនថន: កាលពីដើមឪពុកម្តាយធ្វើអីដែរ?

ម៉ុក: ធ្វើស្រែចម្ការ ។

ប៊ុនថន: ចឹងកាលពូរៀននៅសាលាវត្តតាំងពីឆ្នាំ១៩៦៥ហ្នឹង ក្រោយពីរៀនហើយពីទៅណាទៀត?

ម៉ុក: នៅធ្វើស្រែចម្ការហ្នឹង ។

ប៊ុនថន: យ៉ាងម៉េចបានពូឈប់ពីសាលាវត្ត?

ម៉ុក: វាអត់មានពីណាធ្វើស្រែចម្ការ ។

ប៊ុនថន: ចឹងឪពុកម្តាយ?

ម៉ុក: ឪពុកម្តាយខ្ញុំ..... ។

ប៊ុនថន: ស្តាប់មិនបាន..... ។

ម៉ុក: ស្តាប់មិនបាន...... ។

ប៊ុនថន: ចឹងគ្រូសារមុនឈ្មោះ អីវិញ?

ម៉ុក: ឈ្មោះ ហិក ។

ប៊ុនថន: គាត់មាននៅរស់ទេ?

ម៉ុក: អត់ ។

ប៊ុនថន: នៅខាងកំពង់ធំនោះ?

ម៉ុក: បាទ ។

ប៊ុនថន: ចឹងបន្ទាប់ពីពូរៀបការហើយពូធ្វើអីដែរ?

ម៉ុក: ការបានតែមួយឆ្នាំខ្ញុំចូលធ្វើទ័ពវាយជាមួយទាហាន លន់ នល់ ។

ប៊ុនថន: ចឹងការហើយមួយឆ្នាំ ចឹងឆ្នាំ៧១ពូចូល?

ម៉ុក: បាទ!៧១ ។

ប៊ុនថន: ចឹងកាលហ្នឹងពូស្ម័គ្រចិត្តឬក៏គេជ្រើសរើស?

ម៉ុក: គេជ្រើសរើស ។

ប៊ុនថន៖ ខាងណាជ្រើសរើសពូ?

ម៉ុក៖ ខាងខ្មែរក្រហមនេះ ខាងតំបន់រំដោះគេនេះ ។

ប៊ុនថន៖ ពូមានស្គាល់ឈ្មោះទេ អ្នកជ្រើសរើសពីណាគេវិញ?

ម៉ុក៖ អ្នកជ្រើសរើសនោះមេភូមិមេឃុំគេនោះ កាលនោះគេបង្កើតទ័ពតាមឃុំអី តែពួកគាត់ស្លាប់អស់ហើយ ។

ប៊ុនថន៖ ចូលដំបូងចូលនៅណាវិញ?

ម៉ុក៖ ខ្ញុំចូលមុនដមបូង ចូលនៅកំពង់ថ្ម គេនាំចូលទៅកំពង់ថ្ម ហើយបានគេបញ្ជូនទៅមុខ ។

ប៊ុនថន៖ កំពង់ថ្មហ្នឹងគេហៅកន្លែងអីវិញ?

ម៉ុក៖ កន្លែងតំបន់ ។

ប៊ុនថន៖ តំបន់ប៉ុន្មាន?

ម៉ុក៖ តំបន់៤ មិនដឹងថាតំបន់ប៉ុន្មានខ្ញុំភ្លេចហើយ ទៅពីហ្នឹងទៅបានគេបញ្ជូនទៅភូមិភាគ តំបន់ប៉ុន្មានទេ ភ្លេចទៅវាយូរហើយ ។

ប៊ុនថន៖ កំពង់ធំដូចជាតំបន់៤០ដាង?

ម៉ុក៖ តំបន់៤៧អីមិនដឹង ។

ប៊ុនថន៖ ភូមិភាគឧត្តរ?

ម៉ុក៖ ភូមិភាគឧត្តរ ។

ប៊ុនថន៖ នៅកំពង់ថ្មហ្នឹងធ្វើអីដែរ?

ម៉ុក៖ នៅរៀននយោបាយបានមួយរយៈ ។

ប៊ុនថន៖ ពីណាគេបង្រៀន?

ម៉ុក៖ ឈ្មោះ សូត្រ គណៈតំបន់ ។

ប៊ុនថន៖ គណៈតំបន់ឈ្មោះអីសូត្រពូ?

ម៉ុក៖ មិនចាំត្រកូលគេ គាត់មិនដឹងថានៅណាទេ ។

ប៊ុនថន៖ គាត់មាននៅរស់ដែរ?

ម៉ុក៖ សព្វថ្ងៃមិនដឹងជាយ៉ាងម៉េចទេ កាលហ្នឹងគាត់បង្រៀន ដល់ចូលធ្វើទ័ពវាយជាមួយទាហាលន់នល់ ។

ប៊ុនថន៖ គាត់បង្រៀនពីនយោបាយពីស្អីខ្លះពូ?

ម៉ុក៖ ទៅរៀនរឿងវាយទ័ពវាយទាហាន លន់ នល់ ហ្នឹង វាយចូលទឹកដីភ្នំពេញ កុំឲ្យអាមេរិចកាំងទៀមទារយកសម្តេច សីហនុ មកវិញ កាលនោះមានទៅទាំងប្រុសទាំងស្រី ។

ប៊ុនថន: ចឹងកាលនោះទៅច្រើនដែរ?

ម៉ុក: អ!ទៅច្រើនណាស់ កាលហ្នឹងសុទ្ធតែលះបង់ទៅ ចុះសម្ដេចធ្លាក់ហើយ ទម្លាក់រដ្ឋប្រហារហើយ រៀននយោបាយចេះ កាលនោះសម្ដេចសីហនុ ហ្នឹងគាត់ឲ្យកូនចៅប្រមូលកម្លាំងវាយជាមួយទាហាលន់ នល់ កាលហ្នឹងគាត់នៅប៉េកាំងទៅ ប្រជាជនខ្មែរហ្នឹងចូលធ្វើទ័ពអស់គ្នាចាស់ៗជំរុញឲ្យកូនចៅទាំងអស់ធ្វើទ័ពវាយយកសម្ដេចឪមកវិញ ហើយសម្ដេចសីហនុ គាត់ក៏ខំស្រែកក្ដែងៗមកពីប៉េកាំងហ្នឹង មានជំនួយគាំងពីកាំភ្លើងគ្រាប់ចិនជួយមក ខំធ្វើទាំងអស់គ្នា ខ្លះស្លាប់ៗខ្លះរស់ក៏រស់ ដល់ពេលឈ្នះទៅ មិនឃើញមុខសម្ដេចសីហនុ ឃើញមុខ ប៉ុល ពត វិញ ។

ប៊ុនថន: បាទ ។

ម៉ុក: ដល់ចឹងវាកើតចេញជាបាយរួមបាយអី បង្កើតសហករណ៍ហ្នឹង មានផាប់មនុស្សបណ្ដោយ ។

ប៊ុនថន: បាទ ។

ម៉ុក: យើងនៅក្នុងកណ្ដាប់ដៃគេ យើងរើទៅណារួចជាប់បាត់ហើយ កាលរៀនសូត្រនយោបាយដំបូងនោះរៀនថា សម្ដេចសីហនុធ្វើប្រធានរណសិរ្សប្រមូលកម្លាំងឲ្យកូនចៅខ្មែរខំធ្វើទ័ពហ្នឹងវាយទាហាន លន់ នក់ ឈ្នះដើម្បីទៀមទារយកសីហនុ មកស្រុកខ្មែរវិញ ។

ប៊ុនថន: ចឹងពូរៀននយោបាយទាក់ទងរឿងហ្នឹងដែរ?

ម៉ុក: បាទ!តែដល់ពេលឈ្នះទៅមិនឃើញសម្ដេចសីហនុ ទៅជាឃើញប៉ុល ពត នេះ ទៅជាឆ្ងល់ទាំងអស់គ្នា កើតទៅជាសហករណ៍ កើតទៅជាស៊ីបាយរួមអីណាវិញ ចឹងចប់បាត់ហើយ ។

ប៊ុនថន: បាទ ។

ម៉ុក: ទ័ពក៏ស៊ីបាយរួម ប្រជាជនក៏ស៊ីបាយរួម ការផាររួមកើតឆ្ងល់ទាំងអស់គ្នា ។

ប៊ុនថន: ពូចូលរៀននយោបាយនៅកំពង់ថ្មហ្នឹងយូរទេ?

ម៉ុក: តែមួយអាទិត្យ គេឲ្យទៅតំបន់ អះ!ទៅភូមិភាគ ។

ប៊ុនថន: ច្រើនគ្នាទេ រៀននយោបាយ ប្រហែលជាប៉ុន្មាន?

ម៉ុក: មកមួយវគ្គមាន៣០០ទៅ៤០០ ចេញមួយវគ្គទៅគេហៅទៅទៀត ។

ប៊ុនថន: ចឹងបន្តគ្នាមករហូត?

ម៉ុក: បាទ!មួយវគ្គៗហ្នឹង គណៈតំបន់បង្រៀន ។

ប៊ុនថន: ពូស្គាល់តែ ពូសូត្រ មួយទេ ក្រៅពីហ្នឹងមានស្គាល់ពីណាទៀតទេ?

ម៉ុក: អត់ស្គាល់ទេ ព្រោះគេចំឡែកៗគេទៅឲ្យចូលរៀនតែពីរបីថ្ងៃ គេបញ្ចេញយើងបាត់ ។

ប៊ុនថន: បាទ ។

ម៉ុកៈ    តែក្មេចឈ្មោះគាត់ទៅណាស់  កាលហ្នឹងបាញ់ត្រង់ណាស់  កាំភ្លើងខ្លី  កាលនោះវត្តដាំងតែម្តងអត់មានខុសមួយគ្រាប់ទេ ។

ប៊ុនថេនៈ  គាត់ពីកែបាញ់?

ម៉ុកៈ    បាទ ។

ប៊ុនថេនៈ  ចឹងតួនាទីគាត់?

ម៉ុកៈ    គាត់ជាគណៈតំបន់ដែរ ។

ប៊ុនថេនៈ  ពីណាមេ?

ម៉ុកៈ    តា  សួ  មេ  តាហ្នឹងខាងយោធា ។

ប៊ុនថេនៈ  ពួកហ្នឹងមានបី  មែនទេ?

ម៉ុកៈ    បាទ ។

ប៊ុនថេនៈ  ខាងយោធា?

ម៉ុកៈ    ខ្ញុំមិនដឹងថា  អីខ្លះទេ  រកនឹកមិនឃើញទេ  គាត់ទាបកគាល់សស្គុះ ។

ប៊ុនថេនៈ  គាត់កាន់ខាងអី  នយោបាយ?

ម៉ុកៈ    យោធាតាហ្នឹង  តាសួ  នយោបាយ ។

ប៊ុនថេនៈ  ខាងណាសេដ្ឋកិច្ច?

ម៉ុកៈ  ពីណាគេ  ក្មេចឈ្មោះ  ឈ្មោះ  អឿន  រកនឹកតាហ្នឹងមិនឃើញនៅចុងៗមាត់ ។

ប៊ុនថេនៈ  គាត់អ្នកស្រុកណាដែរ?

ម៉ុកៈ    គាត់អ្នកខាងជើង  ខាងឃួន ។

ប៊ុនថេនៈ  ខាងណារៀតណាមខាងជើងគាត់ទៅរៀននៅហ្នឹង?

ម៉ុកៈ    បាទ ។

ប៊ុនថេនៈ  ចឹងគាត់រៀនហើយ  គាត់មកទាំងអស់គ្នាដែលទាំងបីនាក់?

ម៉ុកៈ    បាទ ។

ប៊ុនថេនៈ  ចឹងមានស្គាល់ស្រុកគាត់ទេ?

ម៉ុកៈ    អត់ទេ ។

ប៊ុនថេនៈ  ពួមកផ្លូវហ្នឹងមកនៅម្តុំណាវិញ?

ម៉ុកៈ    មកផ្លូវហ្នឹងគេបង្កើតកងនៅហ្នឹងតែម្តង  បង្កើតកងពលកងវរសេនាធំ  ចេញវាយតាមភ្នំចិតតារើស ។

ប៊ុនថេនៈ  នៅម្តុំណាបន្ទាយហ្នឹង?

មុំកៈ	គេនៅក្នុងវត្តដើមព្រៃហ្នឹងតែម្តង គ្រាប់កាំភ្លើងដឹកយកពីចិនមក បង្កើតវរសេនាធំរួចហើយ គេចេញមកហាត់វិញ មកហាត់បានជាកន្លះខែបានចេញមកវាយវិញ មកហាត់នៅភូមិបឹង ។

ប៊ុនថនៈ	ភូមិបឹង?

មុំកៈ	បាទ!បង្កើតនៅវត្តដើមព្រៃ ផ្លូវហ្នឹង មករៀននៅភូមិបឹងបានកន្លះខែហើយចេញវាយតែម្តង កាលហ្នឹង ។

ប៊ុនថនៈ	ភូមិបឹងហ្នឹងនៅផ្លូវដែរ?

មុំកៈ	នៅជិតផ្លូវខាងលើផ្លូវវិញ?

ប៊ុនថនៈ	ប្រហែលជាប៉ុន្មានគីឡូពីវត្តដើមព្រៃ?

មុំកៈ	ប្រហែលជាប៉ុន្មានគីឡូទេ ដើរយប់ស្មានមិនសូវដឹងទេ ហាត់វាយយប់វាយថ្ងៃ ។

ប៊ុនថនៈ	ពីណាអ្នកបង្ហាត់?

មុំកៈ	ឈ្មោះ តា ណាត វាងគាត់សស្តើង ស្រុកគាត់នៅណាទេ នៅក្រចេះមិនដឹង ប្រធានវរៈ ។

ប៊ុនថនៈ	មានដឹងថាត្រកូលគាត់ឈ្មោះអីដែរ?

មុំកៈ	អត់ដឹងទេ ។

ប៊ុនថនៈ	គាត់បង្រៀនផ្នែកនយោបាយ?

មុំកៈ	បាទ ។

ប៊ុនថនៈ	ពូនៅវរៈប៉ុន្មានកាលហ្នឹង?

មុំកៈ	វរៈ៥៣ ។

ប៊ុនថនៈ	ចឹងវរៈ៥៣?

មុំកៈ	បាទ ។

ប៊ុនថនៈ	ចឹងវរសេនាធំ?

មុំកៈ	វរសេនាធំ៣០ប៉ុន្មានទេ វាភ្លេចអស់ហើយ ចប់សង្គ្រាមឡើងប៉ុន្មានរយៈហើយ ។

ប៊ុនថនៈ	កងពលហ្នឹងប៉ុន្មាន?

មុំកៈ	កងពលនៅ៨០១ហ្នឹង?

ប៊ុនថនៈ	ចឹងកងពល៨០១តាំងពីពូនៅខាងផ្លូវហ្នឹងទេ?

មុំកៈ	មុនខ្ញុំនៅកងពលភូមិភាគ ដល់ចូលទៅភ្នំពេញ គេបញ្ជូនទៅ៨០១ ។

ប៊ុនថនៈ	កាលហ្នឹងពូនៅភូមិភាគឧត្តរ?

មុំកៈ	បាទ ។

ប៊ុនថនៈ	ភូមិភាគកណ្តាល?

មុ៉កៈ ភូមិភាគខត្តុរ ដល់ឈ្នះភ្នំពេញ គេដកឲ្យទៅរតនគិរី ចេញពីកងពលទៅនៅ៨០១ ។

ប៊ុនថន: ភូមិភាគខត្តរ កុយ ធួន?

មុ៉កៈ បាទ!កាលនោះកងពលជាមួយ តាអឿន កាលនោះ ។

ប៊ុនថនៈ ពូនៅជាមួយពីណា?

មុ៉កៈ នៅជាមួយតាអឿន ។

ប៊ុនថនៈ តាអឿន ខាងយោធា?

មុ៉កៈ បាទ!...................... ។

ប៊ុនថនៈ ខាងខត្តរមានប៉ុន្មានកងពល?

មុ៉កៈ មានបីកងពល ។

ប៊ុនថនៈ ចឹងកាលមុខព្រួញវាយពីណាខ្លះទៅ?

មុ៉កៈ មុខព្រួញខ្ញុំវាយតាំងពីកំពង់ធំកំពង់ថ្មទៅ រហូតដល់ព្រែកក្ដាមវាយចូលតាមភ្នំចិតតាវើស ភ្នំប្រសិទ្ធ តាំងក្រសាំងរហូតដល់ពោធិចិនតុងដល់ភ្នំពេញតែម្ដង ។

ប៊ុនថនៈ ភ្នំប្រសិទ្ធ ចិតតាវើស?

មុ៉កៈ បាទ ។

ប៊ុនថនៈ ចឹងកងពលទី២ តាឈិនអី វាយពីណាទៅ?

មុ៉កៈ វាយពីដើងទៅទាំងអស់ ។

ប៊ុនថនៈ តាផ្លូវជាតិលេខ៥ហ្នឹង?

មុ៉កៈ បាទ!តាមផ្លូវលេខ៦ ហើយមកពីខាងលិចនោះភូមិភាគពិសេស ខាងត្បូងមកពីនោះខាងបូព៌ា ភូមិភាគខាងនោះ ខាងអ្នកលឿងអីខាងបូព៌ាហើយ ខាងនេះមកខាងភូមិភាគពិសេស មានបួនភាគរួមគ្នាវាយយកភ្នំពេញ ។

ប៊ុនថនៈ កាលហ្នឹងមានរៀនចំផែនការអីទេ ផែនការវាយ រៀបចំមុខព្រួញវាយ មានប្រជុំអីទេ?

មុ៉កៈ ប្រជុំ ទទួលមុខព្រួញវាយត្រឹមណា មុនព្រួញខត្តរទទួលត្រឹមណា មុនព្រួញភូមិភាគពិសេសទទួលត្រឹមណា មុខព្រួញភូមិភាគបូព៌ាទទួលត្រឹមណា បែកគ្នាតើ តែវាយចូលបុក ចូលដល់មុនគេមានមុខព្រួញខត្តរ ចូលតាមគីឡូលេខ៦ ។

ប៊ុនថនៈ គីឡូលេខ៦?

មុ៉កៈ បាទ!ចូលពីព្រែកព្នៅទៅ វាយចូលតាមភ្នំចិតតាវើស ខត្តុគ លង្វែក ។

ប៊ុនថនៈ មានស្លាប់ច្រើនទេ?

ម៉ុកៈ ស្លាប់និងលែងនិយាយហើយ ស្លាប់ច្រើនណាស់ ស្លាប់ដល់ហើយ ខ្ញុំរបួសស្មាដល់រាល់ថ្ងៃ ដល់គីឡូលេខ៦ ទាហានលន់ នល់ បាក់ទ័ពអស់ហើយ ។

ប៊ុនថនៈ ទាហានលន់ នល់?

ម៉ុកៈ បាទ! បាក់ទ័ពដេញចូលដល់ផ្សារថ្មី កាលហ្នឹងខ្ញុំចូលបីនាក់ពីរទៀតងាប់ ខ្ញុំបាក់ស្មា ។

ប៊ុនថនៈ ចឹងស្លាប់តែពីរនាក់ហ្នឹងទេ?

ម៉ុកៈ បាទ! ម៉ាទៅជាមួយខ្ញុំស្លាប់ពីរនាក់ ខ្ញុំរបួសធ្ងន់ ក្រៅពីពួកខ្ញុំមិនដឹងយ៉ាងម៉េចទេ ពួកមាន៣ៗ ពេលឈ្នះហើយរបួសដេកពេទ្យហ្នឹងបណ្តោយទៅ ពេទ្យព្រះកេតុមាលា ។

ប៊ុនថនៈ កាលហ្នឹងពូទទួលនាទីអីវិញ?

ម៉ុកៈ ខ្ញុំកាលហ្នឹងកងធំ ។

ប៊ុនថនៈ ប្រធានកងធំ?

ម៉ុកៈ បាទ ។

ប៊ុនថនៈ កងធំលេខប៉ុន្មាន?

ម៉ុកៈ កងធំលេខ១១ដឹងទេ យូរទៅវាភ្លេច ។

ប៊ុនថនៈ កងវរសេនាធំ?

ម៉ុកៈ កងធំ មួយវរសេនាតូច មួយវរសេនាធំ កងធំមានតែ១០០នាក់ពីដើម ។

ប៊ុនថនៈ ចឹងគេអត់មានរៀបកងវរសេនាតូចអីទេ?

ម៉ុកៈ មានក្រុម មានកងតូច មានកងធំ បានមកវរសេនាតូច បានមកវរសេនាធំ បានមកដល់កងពល អត់មានរៀបដូចយើងសព្វថ្ងៃទេ ។

ប៊ុនថនៈ ចឹងកងធំមិនដឹងលេខប៉ុន្មាន?

ម៉ុកៈ កងធំក្តាប់បីកងតូច ។

ប៊ុនថនៈ ចឹងអត់មានលេខទេ?

ម៉ុកៈ មានតែវាភ្លេចទៅណាស់ វាយូរពេកហើយ ។

ប៊ុនថនៈ ពូឡើងប្រធានតាំងពីណាមក?

ម៉ុកៈ ខ្ញុំឡើងពេលខ្ញុំវាយនៅព្រៃកក្តាមហ្នឹង កាលពីដើមខ្ញុំកាន់ក្រុម ហើយគេឲ្យកាន់កងតូចបានប៉ុន្មានខែទេ ជិតមួយឆ្នាំទៅបានវាយតាមមាត់ទន្លេអស់ គេឲ្យខ្ញុំឡើងកងធំ ។

ប៊ុនថនៈ ជិតដាច់ភ្នំពេញហើយ?

ម៉ុកៈ ជិតដាច់ហើយ ។

ប៊ុនថនៈ ឡើងកងធំ?

មុ៉កៈ បាទ!តែកាលនោះទ័ពខ្មែរក្រហម អ្នកណាមិនចេះអក្សរក៏ដោយអ្នកណាហ៊ានខាងវាយឲ្យឡើងតែម្តងណា ។

ប៊ុនថនៈ ចឹងអត់មានរើសតាមអ្នកចេះអីទេ?

មុ៉កៈ អត់ទេ ។

ប៊ុនថនៈ ឲ្យតែមានសមត្ថភាពដឹកនាំក្លាហានគេឲ្យឡើងតែម្តង?

មុ៉កៈ បាទ ។

ប៊ុនថនៈ ចុះកិច្ចការទូទៅអីធ្វើយ៉ាងម៉េចទៅ ឧទាហរណ៍មិនចេះអក្សរចឹង?

មុ៉កៈ គេឲ្យមានស្មៀនឯកមួយ ។

ប៊ុនថនៈ ចឹងមានស្មៀនចាំកត់ត្រាអី?

មុ៉កៈ បាទ!តែយើងមិនចេះអក្សរយើងមិនចង់ធ្វើទេ មកខាងលើគេអត់ព្រមគេឲ្យធ្វើ យើងអ្នកការងារសកម្មប្រយុទ្ធគេឲ្យធ្វើ តែយើងខ្សោយខាងវប្បធម៌យើងមិនចង់ធ្វើទេ រឿងចេះមិនចេះគេមិននិយាយទេ គេឲ្យមានស្មៀនឯកមួយកត់ត្រាអី យើងការងារសកម្មហើយយើងក្លាហានគេមើលឃើញគេតម្លើងឲ្យ ។

ប៊ុនថនៈ ចឹងបើកងពលនេះក្តាប់រួមតាធុច?

មុ៉កៈ តា ពក តាពក គណៈភូមិភាគ ។

ប៊ុនថនៈ គាត់គណៈភូមិភាគ?

មុ៉កៈ បាទ!ភូមិភាគឧត្តរហ្នឹងតាពក ទេ ខាងឧត្តរតាពក ។

ប៊ុនថនៈ គាត់ក្តាប់តាំងពីណាមក?

មុ៉កៈ ក្តាប់ភូមិភាគឧត្តរហ្នឹងហើយ ។

ប៊ុនថនៈ តាំងពីឆ្នាំណា?

មុ៉កៈ ទេ តាំងពីកើតសង្គ្រាមហ្នឹងមកហើយ គាត់ក្តាប់ហ្នឹង ។

ប៊ុនថនៈ ពួកហ្នឹងមានជួប.......

មុ៉កៈ ស្តាប់មិនបាន......... ពេលឈ្នះភ្នំពេញហើយ ឃើញឡើងកាន់អំណាច ជាប៉ុល ពត ក្រោយមកមេៗធំអីហ្នឹងប្រធានកងពលចេះតែដកបាត់អស់ម្តងមួយម្តងពីរ ភូមិភាគថាក្បត់ ឃើញមានបាយរួមគ្រប់ភូមិគ្រប់ឃុំ ទ័ពអីបាយបបររួមអស់បាត់ ខ្ញុំឆ្ងល់ដែលណា កើតមានប៉ុល ពត កើតមានបាយរួមអីណា ។

ប៊ុនថនៈ ចង់សួរពូបន្តទៀត ពេលវាយចូលភ្នំពេញហ្នឹង ខាងណាវាយចូលដល់មុនគេ?

មុ៉កៈ ខាងឧត្តរហ្នឹង ។

ប៊ុនថន៖ ចឹងពូអត់មានចូលជាមួយគេទេ?

ម៉ុក៖ ចូលតែត្រូវរបួសហើយ មិនបានចូលដល់ក្នុង ព្រោះខ្ញុំត្រូវរបួសហើយ របួសបាក់ស្មា ។

ប៊ុនថន៖ ចឹងមកចាប់ដៃគ្នានៅណាវិញ?

ម៉ុក៖ ស្តាប់មិនបាន……ដល់ខ្ញុំជារបួសហើយក៏គេរៀបចំទ័ពដល់ចឹងដកខ្ញុំចូលទៅកងពល៨០១ជាតា០៥វិញ ។

ប៊ុនថន៖ ម៉េចបានគេដាក់ពូទៅកងពល៨០១វិញ?

ម៉ុក៖ គេប្រឡូកគ្នាយ៉ាងម៉េចទេ កងពល៨០១ហ្នឹង គេខ្វះកម្លាំង គេចំរាញ់តាមកងពល ។

ប៊ុនថន៖ ចំរាញ់អ្នកមានស្មាដៃឬយ៉ាងម៉េច?

ម៉ុក៖ និយាយឲ្យចំថាខ្វះកម្លាំង ពេលទៅដល់រតនគិរីចាញ់ងាប់ចង់អស់ ងាប់អស់មិនចេះតិចចាញ់ ។

ប៊ុនថន៖ ពេលពូត្រឡប់មកក្រោយវិញ ពូដេកពេទ្យព្រះកេតុមាលារយៈពេលប៉ុន្មាន?

ម៉ុក៖ រយៈពេលមួយខែ មួយខែជាងបានគេរៀបចំទ័ពទៅ ។

ប៊ុនថន៖ មន្ទីរពេទ្យព្រះកេតុមាលាហ្នឹង ជំនាន់ពូសម្រាកព្យាបាលគេហៅពេទ្យ"ព ប៉ុន្មាន?"

ម៉ុក៖ មិនជាពប៉ុន្មានទេ បើពេទ្យរុស្សីគេហៅពេទ្យ១៧មេសា ។

ប៊ុនថន៖ ពេទ្យកាលម៉ែត្រ?

ម៉ុក៖ ពេទ្យកាលម៉ែត្រគេហៅកាលម៉ែត្រចឹងតែម្តង ។

ប៊ុនថន៖ ពូចេញពីពេទ្យ ពូទៅកងពូ?

ម៉ុក៖ បាទ! ចេញទៅកងពល៨០១ ។

ប៊ុនថន៖ ចឹងមេពូ តាអឿន អីនោះ?

ម៉ុក៖ គេនៅភ្នំពេញ ។

ប៊ុនថន៖ គាត់នៅកងពលលេខ១ដដែល?

ម៉ុក៖ បាទ ។

ប៊ុនថន៖ កងពល៨០១បោះទីតាំងនៅណា កាលនៅភ្នំពេញ?

ម៉ុក៖ នៅខាងត្បូងស្តាតអូឡាំពិជ ខាងកើតខាងបូព៌ា ។

ប៊ុនថន៖ ចឹងពូចេញពីពេទ្យភ្លាម ពូទៅ៨០១?

ម៉ុក៖ អត់ទេ នៅយូរដែលខ្ញុំនៅមួយខែជាង ។

ប៊ុនថន៖ ខាងមេបញ្ជូនទៅតែម្តងឬយ៉ាងម៉េច?

ម៉ុក៖ អត់ទេ គេសុំជ្រើសរើសយកតាមកងពល យកកម្លាំងទៅកើត ។

ប៊ុនថន៖ ពីណាមកជ្រើសរើស?

មុ៉កៈ មេខាង០៥ ក្រោមបញ្ជាគា០៥ទាំងអស់ដែរ គាត់ត្រូវការគាត់សុំខាងណាៗទៅ ។

ប៊ុនថនៈ ចឹងកាលហ្នឹងពូចង់ទៅទេ ពូធ្លាប់នៅកងចាស់?

មុ៉កៈ និយាយរួមអត់ចង់ទេ តែគេឲ្យយើងរៀនឆ្អិនខាងនយោបាយ គេថាទោះបីយ៉ាងម៉េច ចង់មិនចង់ក៏ត្រូវតែទៅ យើងយល់ខ្លួនយើងតែម្ដង ។

ប៊ុនថនៈ បាទ ។

មុ៉កៈ យើងដាច់ខាតខ្លួនយើង តែកាលផ្ញើហ្នឹងពីរក្រុម ។

ប៊ុនថនៈ ចឹងកងពលចាស់ តាអឿន អីគាត់យ៉ាងម៉េចដែរ ស្រឡាញ់កូនចៅ?

មុ៉កៈ ស្រឡាញ់កូនចៅ ។

ប៊ុនថនៈ គាត់អ្នកនៅណាដែរ?

មុ៉កៈ គ្រប់ខេត្តបញ្ចូនជាមួយគ្នា សុទ្ធតែអត់ស្គាល់ទាំងអស់ ដល់យើងយូរបានស្គាល់គ្នាខ្លះ អ្នកណានៅខេត្តណាអ្នកណានៅខេត្តណា ចូលជាមួយគ្នាទាំងអស់ ។

ប៊ុនថនៈ មួយកងពលពូ កងពលលេខ១ហ្នឹង ជ្រើសទៅប៉ុន្មាននាក់ ចូលទៅ៨០១?

មុ៉កៈ ប្រហែលជា២០០នាក់ មួយវរសេនាតូចយក១០នាក់អីទៅ ព្រោះកាលនោះមួយវរសេនាធំវាមានបីវរសេនាតូច ហើយមួយកងពលហ្នឹងវាមានបីវរសេនាធំ ចឹងច្រើនដែលហ្នឹង ។

ប៊ុនថនៈ មួយកងពលមាន៣០០០នាក់ទេ?

មុ៉កៈ បាទ!មួយវរសេនាធំមានបីវរសេនាតូច មួយវរសេនាតូចមាន៣០០ហើយ ចឹងមានច្រើនមានក្រុម កងតូច កងធំ វរសេនាតូច វរសេនាធំ ដល់កងពល យកតាមចិននោះ ។

ប៊ុនថនៈ យកតាមចិនវិញ?

មុ៉កៈ បាទ!ជំនាន់នេះគេរៀបផ្សេង ។

ប៊ុនថនៈ ចឹងពូចូលទៅ៨០១ហ្នឹងនៅឆ្នាំ៧៥ទេ?

មុ៉កៈ បាទ!៧៥ហ្នឹង ។

ប៊ុនថនៈ ៧៥ដាច់បានប៉ុន្មានខែ?

មុ៉កៈ ប្រហែលជាពីរបីខែហ្នឹង ។

ប៊ុនថនៈ ចឹងមកនៅ៨០១ភ្លាមបញ្ជូនទៅភ្លាមឬមួយនៅ៨០១មួយរយៈ?

មុ៉កៈ ទៅក្នុងឆ្នាំ៧៥ហ្នឹង នៅមួយរយៈ ។

ប៊ុនថនៈ ចេញពីកងចាស់របស់ពូកងពលទី១ហ្នឹងមកកងពល៨០១ បញ្ជូនទៅរតនគិរីតែម្ដង នៅក្នុងឆ្នាំ៧៥ហ្នឹង?

មុ៉កៈ បាទ!ឆ្នាំ៧៥ជិតចូលឆ្នាំ៧៦ ។

ប៊ុនថន: ចឹងពូនៅមួយរយៈហើយបានទៅរតនគិរី?

ម៉ុក: បាទ!ចុះដាប់រលំរៀបចំទីក្រុង រៀបចំក្រុងអីស្រួលបួលអស់ហើយបានទៅ ជិះកាណូតទៅ ។

ប៊ុនថន: ចឹងពូនៅ៨០ ១ហ្នឹងនៅរៀបចំក្រុង?

ម៉ុក: អត់ទេ ខ្ញុំរៀបចំក្រុងនៅក្នុងកងពលចាស់រួចហើយ ដល់ហើយកម្ទាំងខាងកើតគេដកខ្ញុំទៅក្រុង គេរៀបចំអស់ហើយ ។

ប៊ុនថន: ចឹងពូនៅកងពលចាស់ហ្នឹងរៀបក្រុងហើយបានបញ្ជូនមកកងពល៨០ ១បានចេញទៅតែម្តង?

ម៉ុក: បាទ ។

ប៊ុនថន: ចឹងប្រហែលជាឆ្នាំ៧៦មែនទេ បានបញ្ជូលមក៨០ ១?

ម៉ុក: បាទ! ហើយនិយាយទៅកើតហ្នឹងអាចចុង៧៦ហើយ ។

ប៊ុនថន: ចឹងពេលបញ្ជូលហើយពូទៅតែម្តង?

ម៉ុក: បញ្ជូលហើយបាន១០ថ្ងៃបានចេញទៅ ។

ប៊ុនថន: ចឹងពូទៅដល់រតនគិរី ពូទទួលកងធំដែលឬកងតូច?

ម៉ុក: កងធំ ។

ប៊ុនថន: ពូទៅឈរនៅរតនគិរីនៅម្តុំណា?

ម៉ុក: ម្តុំណាទេ ខ្ញុំអត់ស្គាល់ដែរ ។

ប៊ុនថន: ស្រុកអីវិញ?

ម៉ុក: ស្រុកអីទេ អត់ចាំ ។

ប៊ុនថន: នៅរតនគិរី ស្រុកវឹនសៃឬមិនមែនទេ?

ម៉ុក: ស្តាប់មិនបាន.... ។

ប៊ុនថន: នៅខាងព្រំដែនឡាវឬព្រំដែនវៀតណាមឬនៅកន្ទុយនាគ?

ម៉ុក: ពិបាកប្រាប់ណាស់ កងពលនៅមួយកន្លែង តែកងទ័ពមួយវរៈនៅនេះ មយយវរៈនៅនោះ នៅតាមព្រំដែន តែរកកន្លែងចំណាំមិនឃើញ ។

ប៊ុនថន: ពូនៅវរសេនាធំលេខប៉ុន្មាន?

ម៉ុក: ៨២មិនដឹង៨៣មិនដឹងទេ ។

ប៊ុនថន: ចឹងពូនៅ៨៣?

ម៉ុក: បាទ!៨៣ ។

ប៊ុនថន: ពីណាប្រធានវរសេនាធំ?

ម៉ុក: ស្តាប់មិនបាន............

ប៊ុនថន៖ ចឹងពេលទៅហ្នឹង ចុះគ្រួសារពូ?

ម៉ុក៖ គ្រួសារខ្ញុំនៅស្រុក ។

ប៊ុនថន៖ ចឹងពូចេញមកផុតរហូតតែម្ដង?

ម៉ុក៖ បាទ! គ្រួសារនេះខ្ញុំទើបយកក្រោយទេ ខ្ញុំឆ្នាំ៩៨ អូស! ប្រទ្បុំខ្ញុំយក៩៣ជិនាន់អ៊ុនតាក់ខ្ញុំយកកាលនៅស្រុកថៃនោះ ។

ប៊ុនថន៖ ចឹងកាលឆ្នាំ៩៣ហ្នឹងពូឈរជើងនៅណាវិញ?

ម៉ុក៖ ខ្ញុំនៅរតនគិរី ....................គេដកខ្ញុំទេ ។

ប៊ុនថន៖ ចឹងគេដកពូនៅឆ្នាំណា?

ម៉ុក៖ គេដកខ្ញុំនៅឆ្នាំ៨៤-៨៥ មកបង្កើតកងពិសេស៨០២វិញ....... ។

ប៊ុនថន៖ ចឹងពូនៅហ្នឹងមានវាយគ្នាខ្លាំងទេ?

ម៉ុក៖ វាយតើ វាយពួកខ្ញុំរត់ចូលដីថៃ ដល់ក្រោយមកទៀត៨០១និង៨០២គេឲ្យចុះមកវិញកាលហ្នឹងវាយខ្លាំងណាស់ ។

ប៊ុនថន៖ ចឹងពូនៅរតនគិរីហ្នឹងនៅកងពល៨០១ហ្នឹងនៅឈរជើងរតនគិរី?

ម៉ុក៖ បាទ ។

ប៊ុនថន៖ ចុះមណ្ឌលគិរីស្ទឹងត្រែងអីពីណា?

ម៉ុក៖ កងពល៨០១ទាំងអស់ហ្នឹងតែបែងចែកគ្នា ។

ប៊ុនថន៖ ចឹងនៅហ្នឹងពូស្គាល់អ្នកខ្សែងទេ?

ម៉ុក៖ ជី មិនស្គាល់ ។

ប៊ុនថន៖ ចឹងពូអត់មានឈរនៅខាងអ្នកខ្សែងទេ?

ម៉ុក៖ អត់ទេ ។

ប៊ុនថន៖ ចឹងកាលនៅហ្នឹងមេៗមានការផ្លាស់ប្ដូរទេ?

ម៉ុក៖ ផ្លាស់ ។

ប៊ុនថន៖ ចឹងផ្លាស់ដែរ គេផ្លាស់យកទៅណាវិញពូ?

ម៉ុក៖ មានយកទៅណាដូចខ្ញុំដកពី៨០១មកចូល៨០២វិញ ចឹង៨០២ហ្នឹងសុទ្ធតែមកពី៨០១ដែរ សុទ្ធតែវរសេនាធំអីហ្នឹងមកបង្កើតធ្វើជាកងពល កូនចៅតា០៥ទាំងអស់ ចេញពី៨០១មកដែរ ៨០១គេធ្វើកងពលបង្កើតជាកងពិសេស៨០១ទេ ៨០២ហ្នឹង ។

ប៊ុនថន៖ ចឹងជាកងពិសេសរបស់៨០១?

ម៉ុក៖ បាទ ។

ប៊ុនថន៖ ដល់ពេលក្រោយមកគេផ្លាច់ពី៨០១ទៅកងពិសេសហ្នឹងទៅកងពល៨០២?

ម៉ុក៖ បាទ! គេមើលថា ពីណាខ្លាំងគេដកយកទៅទៀត ខ្លះដកទៅចូល៩២០ ។

ប៊ុនថន៖ ចឹងមានបាត់អីទេ អ្នកនៅខាងយោធាឬកងពលអី មានបាត់មានចាប់អីទេ?

ម៉ុក៖ មានមិនអត់ទេ តែបាត់ហ្នឹងនិងជាស្លាប់ឬចាប់ ។

ប៊ុនថន៖ ចាប់យកទៅខាងណាវិញ គេចាប់យកដាក់នៅណា?

ម៉ុក៖ ចាប់យកមកអីភ្នំពេញ គេថាក្បត់បេះក្បត់ចុះនោះ មេៗគេចាប់យកមកភ្នំពេញ ។

ប៊ុនថន៖ ចឹងនៅកងពលពូមានបាត់ទេ?

ម៉ុក៖ អត់ទេ កងខ្ញុំអត់ឃើញមានបាត់ មានតែវាយគ្នាស្លាប់ ។

ប៊ុនថន៖ មានស្លាប់នៅក្នុងសមរភូមិ?

ម៉ុក៖ ស្លាប់ គេហៅទៅអត់ឃើញមកវិញ ។

ប៊ុនថន៖ ពីណាហៅទៅ?

ម៉ុក៖ រដ្ឋគេ គេហៅមកភ្នំពេញហ្នឹង តាមដឹងគេហៅតា០៥មកចាប់ តែគាត់ដឹង គាត់អត់មក កាលហ្នឹងពិបាកណាស់ យូរទៅៗថាអា នេះក្បត់ ថាអានោះក្បត់មានពីណាមួយល្អ ។

ប៊ុនថន៖ យ៉ាងម៉េចបានគេចង់ចាប់គាត់ពូ តា០៥?

ម៉ុក៖ គេថាក្បត់ ។

ប៊ុនថន៖ មានពីណាខ្លះ?

ម៉ុក៖ កាលហ្នឹងគណៈភូមិភាគ គណៈតំបន់គេចុះចាប់ទាំងអស់ ។

ប៊ុនថន៖ ខាងណាគេចុះទៅចាប់ពូ?

ម៉ុក៖ ទេ បើចាប់ស្រុក ខាងមានខាងតំបន់ខាងភូមិភាគទៅចាប់ ។

ប៊ុនថន៖ ខាងកងទ័ពចាប់ឬយ៉ាងម៉េច?

ម៉ុក៖ អត់ទេ អត់មានខាងកងទ័ព ខាងរដ្ឋអំណាច ដូចថាចាប់ស្រុក ចាប់គណៈតំបន់ភូមិភាគទៅចាប់ ដល់ចាប់ភូមិភាគមិនដឹងថាខាងណាជាអ្នកចាប់ ខ្ញុំឆ្ងល់ដែរ ។

ប៊ុនថន៖ បាទ ។

ម៉ុក៖ ពិបាកណាស់ ដូចខ្ញុំទ័ពអីសុំមកលេងផ្ទះមិនបានទេ មកលេងផ្ទះគេថាយើងក្បត់វាពិបាកចឹង ទៀត ។

ប៊ុនថន៖ លោកពូមានឃើញចុះទៅចាប់ផ្ទាល់ទេ?

ម៉ុក៖ អត់ទេ តែមួយរយៈក្រោយមកខ្ញុំធ្លាប់ឃើញចាប់ដាក់ឡានផ្ទាល់ដែរ ។

ប៊ុនថន៖ ចាប់ពីណា?

មុំកៈ ទ័ពក៏ចាប់ប្រជាជនក៏ចាប់ ។

ប៊ុនថនៈ និយាយថាចាប់ដាក់ឡានហ្នឹង ចាប់ពីណាវិញ?

មុំកៈ ដឹងថាចាប់ពីណាទេ ដាក់ឡានយកទៅបាត់ ។

ប៊ុនថនៈ ចាប់តាមកងភូមិ?

មុំកៈ ដូចថាចាប់តាមស្រុក តាមតំបន់អីណា ចៅហ្វាយស្រុកអី គេចាប់ដាក់ឡានយកទៅ ។

ប៊ុនថនៈ ពេលណាឆ្នាំណា?

មុំកៈ ឆ្នាំ៧៧-៧៨ហ្នឹងចាប់ខ្លាំងហើយ ចាប់សម័យបីឆ្នាំហ្នឹង ។

ប៊ុនថនៈ កាលហ្នឹងពូនៅកងទ័ពហើយ ពូមកលេង?

មុំកៈ ខ្ញុំនៅកងទ័ពហើយមកលេងឃើញ មកលេងស្រុកភូមិឃើញ យើងមកដេកពីរយប់ពីយប់ ឃើញ ឃើញគេចាប់ កាលហ្នឹងយើងចុះមកមេឲ្យមកដែរ ។

ប៊ុនថនៈ ចឹងមេឲ្យមក?

មុំកៈ បាទ ។

ប៊ុនថនៈ តែមានលិខិតមានអីទេ?

មុំកៈ ស្តាប់មិនបាន..... ។

ប៊ុនថនៈ ចឹងពូមកតាមរយៈឡាន?

មុំកៈ បាទ!ឡានទ័ព ។

ប៊ុនថនៈ ចឹងគេចេញមកបានយើងមកជាមួយដែរ?

មុំកៈ បាទ ។

ប៊ុនថនៈ ចឹងពេលមកដល់ភូមិឃុំអីគេទទួលយ៉ាងម៉េចទៅ គេមានរាក់ទាក់យើងទេ?

មុំកៈ គេរាក់ទាក់ដែលតើ ដល់យើងទៅវិញគេថាយើងខ្មែរស ។

ប៊ុនថនៈ ដល់ចឹងយ៉ាងម៉េចទៅ?

មុំកៈ ស្តាប់មិនបាន.......គេឲ្យចុះមកដើម្បីឲ្យដឹងដែនការខាងក្រោយ ខាងក្រោយគេចាប់ប្រជាជន វាយច្រើនណាស់ ចឹងទ័ពមកពីមុខគេដឹង ចឹងបានមេមិនចង់ឲ្យទ័ពមកទេ ។

ប៊ុនថនៈ ចឹងដឹងថាខាងក្រោយមានចាប់មនុស្សដែរ?

មុំកៈ ដឹងថា ខាងក្រោយមានចាប់ ខ្ញុំមកបានបីថ្ងៃខ្ញុំមកវិញ ។

ប៊ុនថនៈ ចឹងគ្រួសារពូអត់មានអីទេ?

មុំកៈ អត់អីទេ កាលមកហ្នឹងដំណាំដាំដុះដូចដូង ដូចរបស់របរផ្ទះយើងហ្នឹងបេះយកបាន ខ្ញុំមកលេង ដល់នេះបាន ។

ប៊ុនថន: ចឹងមាន់ទាអីហូបបាន?

ម៉ុក: ហូបបាន ។

ប៊ុនថន: ដល់បែកហើយបានពូទៅលេងស្រុក?

ម៉ុក: កាលនេះគេឲ្យចុះទៅធ្វើការនៅកំពង់ធំនោះបានទៅលេងផ្ទះ ព្រោះនៅជិត ។

ប៊ុនថន: ចឹងមិនមែននៅរតនគិរីទេ ចុះមកធ្វើការហើយបានមកលេងផ្ទះ?

ម៉ុក: បាទ! យើងចុះមកធ្វើការទេ ។

ប៊ុនថន: ចឹងចង់ត្រឡប់សួរពូពេលពូឈរជើងនៅខាងខេត្តរតនគិរី ពូមានប្រយុទ្ធគ្នាទេ?

ម៉ុក: កាលខ្ញុំនៅអត់មានវាយគ្នាទេ ដល់ខ្ញុំដកថយមកទេ បានមានវាយគ្នា ។

ប៊ុនថន: ពូដកមកឆ្នាំណា?

ម៉ុក: ឆ្នាំ៨៥-៨៦ ។

ប៊ុនថន: ពេលវៀតណាមវាយចូលរួចហើយបានដកមក?

ម៉ុក: វាយចូលរួចហើយ ។

ប៊ុនថន: ចឹងពេលវៀតណាមវាយចូលហ្នឹង ពូរត់ទៅណា?

ម៉ុក: ខ្ញុំរត់ទៅថៃ ។

ប៊ុនថន: គេហៅមុំបីហ្នឹង?

ម៉ុក: បាទ! មកនៅមុំបីហ្នឹង ។

ប៊ុនថន: គេឥឡូវគេហៅអី?

ម៉ុក: គេហៅ«គ៧» ចេញពីដីថៃមក យើងបែកចេញពី១០០១ ។

ប៊ុនថន: បាទ ។

ម៉ុក: បែកពីមុំបីហើយ បានទៅនៅជំរំ«គ៧» ។

ប៊ុនថន: ចឹងពេលវៀតណាមវាយចូលបុកដំបូងឆ្នាំ៧៩ពូ?

ម៉ុក: ឆ្នាំ៧៩ ។

ប៊ុនថន: ៧៩ហ្នឹង ពូមិនទាន់រត់ទេ ឬមួយរត់មកមុំបី?

ម៉ុក: អត់រត់ទេ ។

ប៊ុនថន: ចឹងនៅវាយគ្នាតទល់នៅហ្នឹង?

ម៉ុក: វាយគ្នាតទល់នៅហ្នឹង ចេះតែវាយរហូតធ្លាក់មកនៅមុំបីនោះ ។

ប៊ុនថន: ប្រហែលជាប៉ុន្មានឆ្នាំពូ?

ម៉ុក: ប្រហែលមួយឆ្នាំ វាយនៅទប់ទល់ធ្វើការវាយ ដល់ហើយចុះទៅក្នុងវាយអី....... ។

ប៊ុនថនៈ ចឹង៧៩ហ្នឹងពូមិនទាន់ដកភ្លាមទេ នៅវាយទៀត?

ម៉ុកៈ ៧៩មិនទាន់ដកទេ នៅ ។

ប៊ុនថនៈ ចឹងបានរយៈពេលជិតមួយឆ្នាំបានថយមកមុំបី?

ម៉ុកៈ បាទ ។

ប៊ុនថនៈ ដកមកទាំងអស់ឬមួយដកមួយវរសេនាធំ?

ម៉ុកៈ ដកទាំងអស់................................ ។

ប៊ុនថនៈ ចឹង៧៩វាយជាមួយវៀតណាម ដល់៨០បានដកមកទន្លេល្ពៅឬឆ្នាំ៨១បានមកនៅ១០០១ពូ?

ម៉ុកៈ បាទ ។

ប៊ុនថនៈ ចឹងមកដល់១០០១ហ្នឹង ពូនៅក្នុងកងពល៨០១ដដែលឬក៏ដូរ?

ម៉ុកៈ ខ្ញុំនៅ៨០២ ។

ប៊ុនថនៈ ៨០២ដូរឆ្នាំណាពូ?

ម៉ុកៈ ឆ្នាំ៨៤-៨៥ គ្រាន់តែដកចេញពី៨០១មកគេបង្កើត៨០២ហ្នឹង ទ័ពរបស់៨០១ដដែលហ្នឹង តែគេចង់បង្កើតផ្សេងកងពិសេស ។

ប៊ុនថនៈ ចឹងឆ្នាំ៨០ហ្នឹងគេបង្កើត៨០២?

ម៉ុកៈ ខ្ញុំមិនចាំឆ្នាំ៨០ឬ៨២ឬ៨៣ខ្ញុំភ្លេច បង្កើតរួចហើយហ្នឹងឲ្យចុះទៅក្នុងទាំងអស់ ៨០១ចាស់ ៨០២ធ្វើការនៅកំពង់ធំហ្នឹង កំពង់ចាមហ្នឹង បើ៨០២គេឲ្យធ្វើការនៅកំពង់ធំ ខ្ញុំនៅកំពង់បានប៉ុន្មានហ្នឹង គេដកខ្ញុំនៅ៩២០ទៀត នៅព្រៃវែង ស្វាយរៀងទៀត មានច្រើនដំណាក់ នៅជាមួយតា០៦ ដកចេញពី៨០២ ។

ប៊ុនថនៈ ចឹងពូអត់មានចាំច្បាស់ទេ ពេលដកពី៨០១ទៅ៨០២?

ម៉ុកៈ ប្រហែលជា៨០ជាង ។

ប៊ុនថនៈ មុនវៀតណាមវាយខ្លាំងកន្លែងទន្លេល្ពៅ កន្លែងមុំបី?

ម៉ុកៈ បាទ ។

ប៊ុនថនៈ ពូជួបនិងមុខវៀតណាមវាយខ្លាំងទៅនៅដីថៃ?

ម៉ុកៈ ៨០២ហ្នឹងបង្កើតក្រោយតែមិនដឹងជា៨០ប៉ុន្មាន ៨៣ឬ៨៤ទេ ។

ប៊ុនថនៈ ចឹង៨៣-៨៤?

ម៉ុកៈ បាទ ។

ប៊ុនថនៈ ឆ្នាំ៨០ប៉ុន្មានវៀតណាមវាយខ្លាំង ឆ្នាំ៨៥ឬ៨០ប៉ុន្មាន?

មុំកៈ ឆ្នាំ៨៤-៨៥ហ្នឹង នៅទន្លេល្ពៅ ។

ប៊ុនថនៈ ចឹងពូមកនៅ"គ៧" ហើយពូមកធ្វើសកម្មភាពនៅខាងណា?

មុំកៈ ចុះមកធ្វើការនៅកំពង់ធំ ។

ប៊ុនថនៈ ចឹងឆ្នាំ៨៧ដកទៅព្រៃវែង?

មុំកៈ ទៅព្រៃវែង ទៅដល់ហ្នឹងបង្កើតកងទៀត ដាក់កង៨៩ទៀត កង៨៩ ។

ប៊ុនថនៈ គេហៅកង៨៩ឬកងពល៨៩?

មុំកៈ កង៨៩ហ្នឹង គេបង្កើតឆ្នាំ៨៩ហ្នឹងតែម្តង គេដាក់៨៩បណ្តោយលេខ ចឹងរាល់ថ្ងៃគេហៅ៨៩ហ្នឹងភូមិហ្នឹង សុទ្ធពួក៨៩ គេបង្កើតកងលេខហ្នឹងឆ្នាំ៨៩ហ្នឹងឯង ហ្នឹងតាពីន តាពីន នៅខេត្តរាល់ថ្ងៃហ្នឹង ។

ប៊ុនថនៈ ចឹងកង៨៩ហ្នឹង នៅក្នុងកងពល៩២០?

មុំកៈ បាទ!ច្របូកជាមួយ៩២០ ។

ប៊ុនថនៈ បញ្ចូលគ្នាជាមួយ៩២០?

មុំកៈ បាទ!ធ្វើការជាមួយ៩២០ ៩២០ហ្នឹងលេខគេផ្សេងទេ កង៨៩នេះផ្សេង ។

ប៊ុនថនៈ កង៨៩ហ្នឹងពីណាគ្រប់គ្រង?

មុំកៈ តាពីន ។

ប៊ុនថនៈ ចឹង៩២០?

មុំកៈ តាសាន តាសាន ហ្នឹងគាត់បង្កើតកងពលយូរណាស់ហើយ ។

ប៊ុនថនៈ ចឹងពូនៅកង៨៩?

មុំកៈ បាទ!អាហ្នឹងមិនមែនលេខកងពលទេ លេខវរសេនាធំ៨៩ហ្នឹង ។

ប៊ុនថនៈ ចឹងឆ្នាំ៨៩ពូមុខព្រួញស្វាយរៀង ព្រៃវែង?

មុំកៈ បាទ ។

ប៊ុនថនៈ នៅម្តុំណាពូ?

មុំកៈ ស្វាយរៀងនៅសមរភូមិពពែល ឃុំក្រញ៉ូង ដូនតី ទួលទំពែល តាអាន់ អណ្តូងក្រេះ ប៉ុន្មានភូមិ វាវែងរៀបរាប់មិនអស់ តែនៅនោះអត់មានដែលវាយទេ ដើរខាងធ្វើការផ្នែកខាងនយោបាយ ។

ប៊ុនថនៈ ចឹងមានចុះជាប់ខាងកំពង់ចាមទេ?

មុំកៈ បាទ ។

ប៊ុនថនៈ ចឹងមានបីខេត្ត ព្រៃវែង ស្វាយរៀង និងកំពង់ចាម?

ម៉ុកៈ បាទ!កំពង់ចាមខាងស្រុកដំបែរ ខាងស្រែកក់ ។

ប៊ុនថនៈ ខាងព្រៃវែងស្រុកអីវិញពូ?

ម៉ុកៈ ព្រៃវែង ស្រុកកំពង់ត្របែក ភ្លេចអស់ហើយ ។

ប៊ុនថនៈ មានកំចាយមា កំពង់ត្របែក?

ម៉ុកៈ មានកំចាយមា ដូនតី ។

ប៊ុនថនៈ ដូនតី ពញាក្រែក ដូនតី ខេត្តកំពង់ចាម?

ម៉ុកៈ បាទ ។

ប៊ុនថនៈ ស្វាយរៀង ក្រញ៉ូង ស្រុករមាសហែក?

ម៉ុកៈ មុនខ្ញុំចាំតែ ដល់យូរវាភ្លេច ។

ប៊ុនថនៈ ចឹងធ្វើការខាងក្នុងហ្នឹងអប់រំប្រជាជនឲ្យធ្វើអីខ្លះទៅ?

ម៉ុកៈ ស្តាប់មិនបាន.........................................

ប៊ុនថនៈ ចូលទៅតាមភូមិចឹង ប្រជាជនគាត់មានការភ័យខ្លាចទេ?

ម៉ុកៈ ស្តាប់មិនបាន..................................................

ប៊ុនថនៈ ចឹងពេលគាត់ឃើញ គេរត់ទៅរាយការណ៍អី?

ម៉ុកៈ មុនដំបូងគាត់រាយការណ៍ ។

ប៊ុនថនៈ ចឹងពេលចុះទៅតាមភូមិចឹង យើងទំនាក់ទំនងមកខាងក្រោយវរសេនាធំយ៉ាងម៉េចទៅ យើងប្រឡំជាប្រជាជន?

ម៉ុកៈ ស្តាប់មិនបាន.......................................................

ប៊ុនថនៈ ចឹងយើងបោះទីតាំងនៅណាទៅ?

ម៉ុកៈ យើងបោះទីតាំងអត់មានកំណត់ទេ ដូចថានៅខាងត្បូងហ្នឹងនៅក្នុងព្រៃមួយដុំទៅ យប់ឡើងនាំគ្នាចេញដើរទៅមួយក្រុមៗទៅ អ្នកណាទៅភូមិណាអ្នកណាទៅភូមិណាយើងចែកគ្នា ឲ្យតែឃើញកុនហើយ មកវិញទាំងយប់ ។

ប៊ុនថនៈ ចឹងស្នាក់នៅក្នុងព្រៃ?

ម៉ុកៈ បាទ!ស្នាក់នៅក្នុងព្រៃ មានព្រៃអីធំទេ ព្រៃកំប៉េកកំប៉ូតហ្នឹង ។

ប៊ុនថនៈ ចឹងស្បៀងអាហារអីយើងដោះស្រាយយ៉ាងម៉េចទៅ?

ម៉ុកៈ ប្រជាជន ។

ប៊ុនថនៈ ចឹងយើងមានលុយហើយ?

ម៉ុកៈ មានលុយ រដ្ឋគេឲ្យម្នាក់មួយខែអង្ករ២៥គីឡូ ។

ប៊ុនថន: ចឹងអត់មានបើកលុយឲ្យតាម?

ម៉ុក: យើងបើកលុយទិញដូរជាមួយប្រជាជន្ត............ ។

ប៊ុនថន: ហើយម្ហូប?

ម៉ុក: ស្តាប់មិនបាន....................................

ប៊ុនថន: ចឹងប្រជាជនឃើញ?

ម៉ុក: គាត់ឃើញដំបូងគាត់ខ្លាច ដល់ក្រោយមកយើងបំពាក់បំប៉ន នយោបាយ ។

ប៊ុនថន: ចឹងយើងអត់មានសំឡុតអីគាត់ទេ?

ម៉ុក: អត់ទេ អត់មានសំឡុតទេ និយាយល្អជាមួយគាត់ អត់មានសម្លាប់ប្រជាជនឬមួយវាយតប់ អត់មានវាយខ្មែរនិងខ្មែរទេ ថាខ្ញុំវាយតែជាមួយយួនទេ ខ្ញុំមកនេះដើម្បីពុកម៉ែ មកដើម្បីវាយយួនការពារទឹកដី ។

ប៊ុនថន: ចឹងពូចុះទៅខាងស្វាយរៀង ខាងព្រៃវែង កំពង់ត្របែកកំពង់ចាមអីហ្នឹងដល់ពេលណា?

ម៉ុក: ស្តាប់មិនបាន...........................................................................................

ប៊ុនថន: ចឹងពូឡើងមក មកខាងណាវិញ ពេលចេញពីខាងក្នុងមក ពូមកនៅខាងព្រំដែននេះមកនៅខាងណាវិញ?

ម៉ុក: ខ្ញុំមកនៅអូរធំ អត់ទាន់មកនៅនេះទេ ។

ប៊ុនថន: អូរធំបច្ចុប្បន្នគេហៅអីវិញ?

ម៉ុក: គេហៅ១០៥ ។

ប៊ុនថន: ភូមិឃុំអីដែរ?

ម៉ុក: អត់ដឹង ខ្ញុំមិនដែលបានទៅ ។

ប៊ុនថន: នៅស្រុកអីវិញត្រពាំងប្រាសាទឬមួយអន្លង់វែង?

ម៉ុក: អន្លង់វែងទេ យ៉ាង មិនមែនស្រុកត្រពាំងប្រាសាទទេ ឥឡូវស្រុកត្រពាំងប្រាសាទដឹងអ៊ី ខ្ញុំតាំងពីអើយមកខ្ញុំមិនដែលបានទៅជិតសោះ ។

ប៊ុនថន: ចឹងឆ្នាំ៩៣ហ្នឹង ពូមកនៅក្នុងដីខ្មែរទេ?

ម៉ុក: បាទ ។

ប៊ុនថន: ចឹងនៅកងពលដដែលពូមកនៅរួមគ្នាជាមួយកងពល៩២០?

ម៉ុក: មកនៅនេះដកចេញផុត មកនៅ៨៩ដាច់ដោយឡែក ។

ប៊ុនថន: ចឹងមកដល់ហ្នឹងហើយបានដកដាច់ចូល៨៩?

ម៉ុក: ចូល៨៩ផ្តាច់ខ្លួនហើយ ។

ប៊ុនថន: ពេលឆ្នាំ៩៣ មកពូនៅក្នុងក្របខ័ណ្ឌកងពលណា?

ម៉ុក: នៅ៨៩នេះ ការគ្រប់គ្រងពីលើមានតា០៥ តែកងវាដោយឡែកទៅហើយ តែក្តាប់រួមទូទៅមាន០៥ហ្នឹងឯង ។

ប៊ុនថន: ចឹង០៥នៅ៨០១ដដែល?

ម៉ុក: បាទ ។

ប៊ុនថន: ចឹងមេ៨៩តាពីន?

ម៉ុក: តាពីន ។

ប៊ុនថន: គេហៅកងវរសេនាធំ៨៩?

ម៉ុក: ៨៩ តាជិន តាពីន គាត់កាន់កងពល....................

ប៊ុនថន: ចឹងតាជន?

ម៉ុក: ស្តាប់មិនបាន........................................................................... កាលអ៊ុនគាត់ចូលមកខាងខ្មែរក្រហមនេះ អត់មានឈ្មោះ បោះឆ្នោត កាលហ្នឹងខ្មែរក្រហមអត់មានបានបោះឆ្នោតហ្នឹងគេ ដល់ចឹងបោះជាប់តែសម្តេចក្រុមព្រះនិងហ៊ុន សែន គេដុំគ្នាវាយខ្មែរក្រហម ។

ប៊ុនថន: បាទ ។

ម៉ុក: ចាប់វាយគ្នាវិញទៀតហើយពេលនោះ ។

ប៊ុនថន: ចឹងកាលហ្នឹងអ៊ុនគាត់មានមកដល់ហ្នឹងដែរ កាលពូនៅ?

ម៉ុក: មក ។

ប៊ុនថន: ចឹងទាហានអ៊ុនគាត់ ចូលមកដល់អូរធំទេ មកដល់កន្លែងពូទេ?

ម៉ុក: អត់ទេ ។

ប៊ុនថន: ចូលមកអត់បានទេ?

ម៉ុក: អត់ទេ អ៊ុនគាត់ ចូលមកដល់តាមខេត្តតាមស្រុក ។

ប៊ុនថន: ចឹងខាងខ្មែរក្រហមមិនចូលទេ បោះឆ្នោតហ្នឹង?

ម៉ុក: មិនចូល ។

ប៊ុនថន: ម៉េចបានជាមិនចូលពូ?

ម៉ុក: ទេ មិនដឹងជាយ៉ាងម៉េច តែប៉ុល ពត គាត់បញ្ជាឲ្យមានការបោះឆ្នោតតើ ។

ប៊ុនថន: បញ្ជាឲ្យចូលឬយ៉ាងម៉េច?

ម៉ុក: បញ្ជាឲ្យចូលបោះឆ្នោត តែតាម៉ុក ចចេះមិនឲ្យចូលឲ្យវាយ ។

ប៊ុនថន៖ មិនបានគាត់នេះ?

ម៉ុក៖ មិនដឹងយ៉ាងម៉េច គំនិតរបស់គាត់ ។

ប៊ុនថន៖ យ៉ាងម៉េចបានជាពូដឹងថា ប៉ុល ពត គាត់ឲ្យចូល?

ម៉ុក៖ ទេ ទៅរៀនមេៗគេនិយាយថា ប៉ុល ពត ឲ្យចូល តែតាម៉ុក ថាឲ្យវាយ ប៉ុល ពត គាត់ព្រមព្រៀងបោះឆ្នោតហើយតើ តែតាម៉ុក មិនឲ្យចូល តាម៉ុកវាយ ។

ប៊ុនថន៖ ចឹងឲ្យវាយវិញ?

ម៉ុក៖ បាទ ។

ប៊ុនថន៖ ចឹងវាយជាមួយខាងរដ្ឋាភិបាលបោះឆ្នោតហើយ?

ម៉ុក៖ បាទ ។

ប៊ុនថន៖ ឆ្នាំណា?

ម៉ុក៖ ឆ្នាំ៩៨ ។

ប៊ុនថន៖ ចឹង៩៨វាយ?

ម៉ុក៖ ចុះយើងបោះឆ្នោត៩៣ ។

ប៊ុនថន៖ បាទ ។

ម៉ុក៖ ចឹង៩៨វាយ ៩៨ចាប់ផ្ដើមវាយ ពួកខាងហ្នឹងមកវាយខ្មែរក្រហមតែម្ដង ។

ប៊ុនថន៖ ចឹងពូទៅណាជាមួយតាជិន អី?

ម៉ុក៖ ខ្ញុំនៅអូរធំហ្នឹង............... ។

ប៊ុនថន៖ ចឹងដល់មានការអើរត់ទៅខាងថៃ?

ម៉ុក៖ បាទ!...................................ក្រោយមកមានការបែកបាក់គ្នាឯងទៀត ។

ប៊ុនថន៖ ចឹងបែកបាកលជាមួយ០៥អីហ្នឹង?

ម៉ុក៖ ហ្នឹងហើយចាប់តា០៥យកវាយចោល ។

ប៊ុនថន៖ ចឹងដូចជាសុន សេន នោះពីណាជាអ្នកចាប់ មានមូលហេតុអីបានគេសម្លាប់?

ម៉ុក៖ គេថាក្បត់ ចូលយួន គេចាប់ និយាយទៅខ្ញុំមិនសូវដឹងដែរ ខ្ញុំទៅទ័ពនៅមុខនោះ ។

ប៊ុនថន៖ ចឹងអត់សូវដឹងដែរ?

ម៉ុក៖ បាទ!ទ័ពនៅតែមុខជាមួយតាជិន នោះហើយមេៗនៅក្រោយនេះ ។

ប៊ុនថន៖ ចឹងកាលគេសម្លាប់សុន សេន អីពូនៅណា?

ម៉ុក៖ ខ្ញុំនៅខាងមុខនោះ នៅខាងសាអែម គេបញ្ជូនខ្ញុំឲ្យទៅនៅសាអែម ។

ប៊ុនថន៖ ចឹងពេលព្រឹត្តិការណ៍ប៉ុល ពត រដ្ឋប្រហារ?

ម៉ុកៈ កាលរដ្ឋប្រហារហ្នឹងខ្ញុំនៅនោះអត់មានដឹងដែរ ថាមេបែកបាក់គ្នារត់អស់ទៅ.............បែកគ្នាខ្លះរត់ទៅចូលខេត្តអស់ ។

ប៊ុនថនៈ ពូរត់ទៅជាមួយពីណាកាលហ្នឹង ទៅជាមួយតា អ៊ីលាង?

ម៉ុកៈ បាទ!ខ្ញុំធ្វើការជាមួយគាត់ហ្នឹងហើយតែខ្ញុំនៅមុខនោះ............ កាលហ្នឹងតាម៉ុក យកឡានគាត់អាធំៗដើរចាប់យកទៅលើនោះ ចូលខាងប៉ៃលិនវិញ ។

ប៊ុនថនៈ រត់ទៅខាងប៉ៃលិនវិញ?

ម៉ុកៈ ចុះគេផ្តាច់ខ្លួនអស់ហើយ នៅប៉ុន្មាន..........................................

ប៊ុនថនៈ យ៉ាងម៉េចបានជាពូមិនទៅជាមួយគាត់?

ម៉ុកៈ ស្តាប់មិនបាន..............................

ប៊ុនថនៈ ចឹងពេលគេរៀបចំចូលជាមួយរដ្ឋាភិបាលគេមានឲ្យពូចូលកងពលណាវិញ?

ម៉ុកៈ ស្តាប់មិនបាន....................................................................ឥឡូវគេកាត់រំសាយហើយ ។

ប៊ុនថនៈ ចឹងឆ្នាំណាគេកាត់រំសាយ?

ម៉ុកៈ ឆ្នាំ២០០២មិនដឹងអី.........................................

ប៊ុនថនៈ ចឹងពូនៅទាហានទៀតទេ?

ម៉ុកៈ ចប់ហើយ ។

ប៊ុនថនៈ កាត់តាំងពី២០០២បុថ្មីៗនេះ?

ម៉ុកៈ កាត់វគ្គទី២ .............................................

ប៊ុនថនៈ ចឹងក្រោយពីកាត់ហើយពូឈប់ធ្វើការអីទៀតហើយ?

ម៉ុកៈ អត់ទេ ។

ប៊ុនថនៈ ចឹងធ្វើស្រែចម្ការ?

ម៉ុកៈ បាទ ។

ប៊ុនថនៈ ចឹងរាល់ថ្ងៃពូធ្វើអីវិញ?

ម៉ុកៈ អត់ធ្វើអីទេ នៅបើកប្រាក់អាត្រែត ។

ប៊ុនថនៈ ហ្នឹងសម្រាប់អ្នកចូលនិវត្តន៍?

ម៉ុកៈ បាទ ។

ប៊ុនថនៈ ទាហានចូលនិវត្តន៍គេឲ្យប្រាក់សង្គមកិច្ច?

ម៉ុកៈ បាទ ។

ប៊ុនថន: ចឹងពូមកដល់ភូមិនេះឆ្នាំណា?

ម៉ុក: ឆ្នាំ៩៨ ។

ប៊ុនថន: ចឹងសមាហរណ៍កម្មហើយពីមកនៅនេះតែម្ដង?

ម៉ុក: បាទ ។

ប៊ុនថន: ពូសព្វថ្ងៃមានកូនប៉ុន្មាននាក់ដែរ?

ម៉ុក: មានកូនបួននាក់ ។

ប៊ុនថន: ចឹងពូធ្លាប់ឆ្លងកាត់របបខ្មែរក្រហមមកពូមានដែលនិយាយប្រាប់កូនចៅទេ?

ម៉ុក: ស្ដាប់មិនបាន.............................................................

ប៊ុនថន: ចឹងនៅភូមិនេះវត្តអីកើតតាំងពីឆ្នាំណាមក?

ម៉ុក: កើតក្រោយនេះទេ កើតពេលសមាហរណ៍កម្មហើយបានពីរបីឆ្នាំ ។

ប៊ុនថន: ចឹងពីមុនមកអត់មានទេ?

ម៉ុក: អត់មានទេ ។

ប៊ុនថន: ចឹងពូមានបានទៅវត្តអីទេ?

ម៉ុក: ទៅតើ ម៉ាជួរព្រំដែននេះ ភូមិពីមុនមកអត់មានទេ មានតែភូមិសាអែមទេ តំបន់នេះសុទ្ធតែតំបន់ព្រៃទាំងអស់និងមានតែនៅអន្លង់វែងទេ មានផ្ទះពីមុន ។

ប៊ុនថន: បាទ ។

ម៉ុក: ផ្ទះនៅនេះគ្មានទេ ទើបមានឥឡូវនេះទេ ។

ប៊ុនថន: ចឹងកាលពីមុនមកធ្លាប់ឆ្លងកាត់អីមកសម័យហ្នឹង ពូគិតថាខុសគ្នាយ៉ាងម៉េចដែរ?

ម៉ុក: វាគ្រាន់ថាពីមុនមកវាលំបាកហើយ មានសង្គ្រាមវាមានដែលស្រួលអី មកដល់សម័យនេះស្រួល វាលែងភ័យរឿងច្បាំងរឿងអី រាល់ថ្ងៃមានតែចោលបួនអីតិចតួចមាន បើនិយាយពីសង្គ្រាមវាចប់អស់ហើយ ។

ប៊ុនថន: បាទ ។

ម៉ុក: ហើយយើងដើរបានសេរី ។

ប៊ុនថន: ចឹងខ្ញុំអត់អីសួរពូហើយ ពូមានអីចង់និយាយទៀតទេ?

ម៉ុក: អស់ហើយ ។

ប៊ុនថន: ចឹងខ្ញុំអរគុណពីច្រើន ។

ម៉ុក: បាទ ។

**ចប់**